J Trust Royal Bank

# ខចែង និងលក្ខខណ្ឌសម្រាប់ការប្រើប្រាស់ ប្រព័ន្ធបាគងរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

ឧសភា ២០២៣

# មាតិកា

1. លក្ខខណ្ឌទូទៅ ....... 3
2. ពាក្យបច្ចេកទេស និង និយមន័យ ....... 3
3. សេវាកម្មដែលមាន ....... 4
4. បុគ្គលដែលមានសិទ្ធិ ....... 4
5. ការទទួលខុសត្រូវរបស់អតិថិជន ....... 4
6. សុវត្ថិភាពនៃលេខសម្ងាត់ ....... 5
7. សុវត្ថិភាពទូរស័ព្ទចល័តសម្រាប់ចុះឈ្មោះប្រព័ន្ធបាគង ....... 6
8. គណនីបាគង ....... 6
9. លក្ខខណ្ឌនៃការប្រើប្រាស់គណនីបាគង ....... 6
10. សំណង ....... 7
11. ការបញ្ចប់ ឬការលុបចោល ....... 7
12. ថ្លៃសេវា ....... 7
13. ការទូទាត់ និងផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ....... 7
14. ការទទួលខុសត្រូវរបស់ធនាគារ ....... 8
15. ការបង្ហាញអំពីព័ត៌មានគណនី ....... 9
16. ការប្រែប្រួលនៃ ខនិងលក្ខខណ្ឌ និងការកំណត់ថ្លៃ ....... 9
17. លក្ខខណ្ឌផ្សេងៗទៀត ....... 10

## 1. លក្ខខណ្ឌទូទៅ

ខចែង និងលក្ខខណ្ឌទាំងនេះត្រូវបានយកមកអនុវត្ត ក្នុងអំឡុងពេលប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក។ ពិតជាសំខាន់ណាស់ដែលលោកអ្នកបានអានខចែង និងលក្ខខណ្ឌនេះ រួមជាមួយនឹងឯកសារស្តីពី “កម្រៃ និង ការកំណត់ សម្រាប់ការប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគង” “ខចែង និងលក្ខខណ្ឌនៃសេវាធនាគារតាមអ៊ីនធឺណិត និងសេវាធនាគារចល័តរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់” និង ប័ណ្ណផ្សព្វផ្សាយស្តីពីថ្លៃសេវា មុនពេលដែលលោកអ្នកសម្រេចចិត្តប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក។ ប្រសិនលោកអ្នក មិនយល់ ឬមិនច្បាស់អំពីចំណុចចណាមួយនៃខចែង និងលក្ខខណ្ឌនេះ សូមសាកសួរមកកាន់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ដើម្បីទទួលបានការពន្យល់ទាក់ទងនឹងចម្ងល់លោកអ្នក។

សូមអាន ខចែង និង លក្ខខណ្ឌនេះដោយប្រុងប្រយ័ត្ន មុនពេលគូសសញ្ញាធីក (√) ក្នុងប្រអប់ “យល់ព្រម” នៅលើទូរស័ព្ទដៃរបស់លោកអ្នក។ បន្ទាប់ពីចុចក្នុងប្រអប់ “យល់ព្រម” លោកអ្នកបានយល់ព្រមតាម ខចែង និងលក្ខខណ្ឌ ព្រមទាំងការជូនដំណឹងដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ និងទទួលខុសត្រូវចំពោះការប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគង។

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក រក្សាសិទ្ធិក្នុងការកែប្រែផ្នែកខ្លះ ឬទាំងស្រុងនៅក្នុង ខចែង និង លក្ខខណ្ឌ ក៏ដូចជាឯកសារផ្សេងៗទៀត ដូចជា ឯកសារស្តីពី “កម្រៃ និង ការកំណត់ សម្រាប់ការប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគង” “ខចែង និងលក្ខខណ្ឌនៃសេវាធនាគារតាម អ៊ីនធឺណិត និងសេវាធនាគារចល័តរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់” នៅពេលណាមួយ ដោយស្របតាមច្បាប់ជាធរមាន។ លើកលែងតែមានកំណត់នៅក្នុង ខចែង និងលក្ខខណ្ឌនេះ ធនាគារនឹងធ្វើការជូនដំណឹងដល់លោកអ្នកអំពីការផ្លាស់ប្តូរណាមួយដែលអាចប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់លោកអ្នក។

នៅក្នុងឯកសារនេះ ពាក្យ “លោកអ្នក” “របស់លោកអ្នក” សំដៅដល់ម្ចាស់គណនីម្នាក់ ឬច្រើននាក់ ឬម្ចាស់គណនីបាគងដែលប្រើប្រាស់តាមរយៈទូរសព្ទ័ចល័ត។

“យើង” និង “ធនាគារ” សំដៅដល់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក។

## 2. ពាក្យបច្ចេកទេស និង និយមន័យ

ក) **កម្មវិធីបាគង** គឺជាកម្មវិធីប្រតិបត្តិការ សេវាទូទាត់តាមប្រព័ន្ធបាគង ដែលអនុញ្ញាតឲ្យអតិថិជនជាសមាជិកបាគងអាចធ្វើការទាញយក ដើម្បីប្រើប្រាស់មុខងារបាគង។

ខ) **ប្រព័ន្ធបាគង** គឺជាប្រព័ន្ធដែលគ្រប់គ្រងដោយសភាផាត់ទាត់ នៃធនាគារជាតិនៃកម្ពុជា ដែលផ្តល់នូវការតភ្ជាប់រវាងប្រព័ន្ធរបស់សមាជិក ដើម្បីឲ្យអតិថិជនធ្វើប្រតិបត្តិការឆ្លងធនាគារ។

គ) **គណនីបាគង** គឺជាគណនីរបស់អតិថិជនដែលមាននៅក្នុងប្រព័ន្ធបាគង។ គណនីនេះ ត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិ នៅពេលដែលអតិថិជនបានចុះឈ្មោះប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគង។

ឃ) **គណនីទូទាត់បាគង** សំដៅលើគណនីដែលបានបើកជាមួយធនាគារជាតិនៃកម្ពុជាសម្រាប់ធ្វើការទូទាត់។

ង) **គណនីធនាគារ** គឺជាគណនីសន្សំ ឬគណនីចរន្តដែលបើកដោយអតិថិជនដែលជាសមាជិកបាគង។

ច) PIN គឺជាលេខកូដសម្ងាត់ផ្ទាល់ខ្លួន ដែលអតិថិជនអាចបង្កើតបានដោយជ្រើសរើសលេខចាប់ពី ៨ ទៅ ១៦ ខ្ទង់ ដើម្បីចូលទៅកាន់ប្រព័ន្ធបាគង។

ឆ) **កូដ** QR គឺជាលេខកូដសម្រាប់គណនីផ្ទាល់ខ្លួនរបស់អតិថិជន ដែលបង្កើតដោយស្វ័យប្រវត្តិនៅពេលដែលអតិថិជនបានចុះឈ្មោះសម្រាប់ការប្រើប្រាស់សេវាទូទាត់បាគងដោយជោគជ័យ ហើយលេខកូដនេះប្រើប្រាស់សម្រាប់ការទទួលប្រាក់ ឬការទូទាត់ផងដែរ។

## 3. សេវាកម្មដែលមាន

- ពិនិត្យមើលសមតុល្យ និង របាយការណ៍គណនីសង្ខេប
- ផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន (គណនីបាគង ទៅគណនីធនាគារ)
- គណនីបាគង ទៅ គណនីបាគង
- គណនីបាគង ទៅ គណនីធនាគារដទៃ
- ដាក់ប្រាក់ចូលគណនីបាគងនៅតាមបញ្ជរធនាគារ
- ដកប្រាក់ពីគណនីបាគងនៅតាមបញ្ជរធនាគារ
- ការទូទាត់ និង ផ្ទេរប្រាក់បាគងតាមរយៈកូដ KHQR
- សេវាកម្មផ្សេងៗទៀតដែលអាចដាក់ឲ្យដំណើរការដោយធនាគារជាតិនៃកម្ពុជានាពេលអនាគត

## 4. បុគ្គលដែលមានសិទ្ធិ

ក) អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ

ខ) ទូរស័ព្ទចល័តដែលប្រើប្រព័ន្ធប្រតិបត្តិការ iOS ឬ Android និង លេខទូរស័ព្ទ។

គ) ផ្ញើរូបថតសែលហ្វីដោយកាន់អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនដែលមានសុពលភាពយ៉ាងតិច៣ខែ ឬ សៀវភៅគ្រួសារមកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក។

ឃ) យល់ព្រមតាម ខចែង និងលក្ខខណ្ឌសម្រាប់ការប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក។

## 5. ការទទួលខុសត្រូវរបស់អតិថិជន

ក) លោកអ្នកត្រូវទទួលខុសត្រូវលើរាល់ព័ត៌មានដែលបានផ្តល់ឲ្យតាមរយៈទូរសព្ទ័ចល័ត ថាពិតជាមានភាពត្រឹមត្រូវ និងសុក្រិតភាព។ ប្រសិនបើធនាគាររកឃើញថារាល់ព័ត៌មានដែលបានផ្តល់ឲ្យគឺក្លែងក្លាយ នោះលោកអ្នកនឹងត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់។ លោកអ្នកត្រូវទទួលខុសត្រូវការខាតបង់ ឬខូចខាតណាមួយដែលបណ្តាលមកពីសកម្មភាពផ្ទាល់ខ្លួន ឬការប៉ុនប៉ងធ្វើសកម្មភាពណាមួយ ដោយរួមបញ្ចូលទាំងការបាត់បង់ដល់លោកអ្នកផ្ទាល់ ឬអ្នកដទៃ ឬធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក។ ប្រការនេះនឹងត្រូវបានអនុវត្ត ប្រសិនបើលោកអ្នកមានការធ្វេសប្រហែសក្នុងការធ្វើប្រតិបត្តិការ បំភ្លៃព័ត៌មាន ការបោកបន្លំ ឬសកម្មភាពខុសច្បាប់ផ្សេងៗទៀតតែម្នាក់ឯង ឬជាមួយអ្នកដទៃ។ សូមលោកអ្នកត្រូវចងចាំថា លោកអ្នកនៅតែទទួលខុសត្រូវចំពោះមុខច្បាប់ ទោះបីជាសកម្មភាពដែលបានរៀបរាប់ខាងលើត្រូវបានកើតឡើងដោយចេតនា ឬអចេតនាក្តី។

ខ) ដើម្បីអាចប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគងបាន លោកអ្នកតម្រូវឲ្យគោរពតាមច្បាប់ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ដូចជាច្បាប់ពាក់ព័ន្ធផ្សេងៗ។ ការប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគងនៅក្រៅប្រទេសកម្ពុជា គឺជាការទទួលខុសត្រូវផ្ទាល់របស់លោកអ្នក ហើយលោកអ្នកត្រូវតែគោរពតាមច្បាប់ដែលមាននៅក្នុងប្រទេសនោះ។ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មិនធានានូវរាល់ការប្រើប្រាស់សេវាទូទាត់បាគងនៅប្រទេសដទៃឡើយ។

គ) លោកអ្នក ព្រមទទួលចាត់រាល់វិធានការប្រុងប្រយ័ត្ននានា ដើម្បីធានាសុវត្ថិភាព សន្តិសុខ និងសុចរិតភាពនៃគណនី និងប្រតិបត្តិការនានា នៅពេលប្រើប្រាស់សេវាទូទាត់តាមប្រព័ន្ធបាគង។

ឃ) លោកអ្នកត្រូវតែគោរពតាមរាល់ ខ និងលក្ខខណ្ឌទាំងអស់នេះ ជាពិសេសទាក់ទងទៅនឹងការប្រើប្រាស់លេខកូដសម្ងាត់ផ្ទាល់ខ្លួន (PIN) និងការប្រើប្រាស់កម្មវិធីបាគងឲ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព ដើម្បីជៀសផុតពីប្រតិបត្តិការដែលគ្មានការអនុញ្ញាត្តិ។ វាពិតជាសំខាន់ក្នុងការប្រើប្រាស់កម្មវិធីបាគង ជាមួយនឹងទូរស័ព្ទចល័តផ្ទាល់ខ្លួន ដែលលោកអ្នកបានចុះឈ្មោះសម្រាប់ការប្រើប្រាស់។

ង) លោកអ្នក ត្រូវតែជូនដំណឹងមកធនាគារភ្លាមៗ ក្នុងករណីដែលលេខសម្ងាត់ត្រូវបានគេដឹង ឬមានគេចូលប្រើប្រាស់សេវាទូទាត់បាគង តាមរយៈទូរស័ព្ទដៃរបស់លោកអ្នក ដោយគ្មានការអនុញ្ញាត្តិ។ លោកអ្នក ត្រូវទទួលខុសត្រូវ ប្រសិនបើមានការខាតបង់ណាមួយដែលបណ្តាលមកពីករណីទាំងអស់នេះ។

## 6. សុវត្ថិភាពនៃលេខសម្ងាត់

លោកអ្នក ត្រូវតែរក្សាលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) របស់អ្នកឱ្យមានសុវត្ថិភាព។ ការខកខានក្នុងការធ្វើដូច្នេះ លោកអ្នកត្រូវទទួលខុសត្រូវចំពោះការបាត់បង់ណាមួយ។

លោកអ្នក ត្រូវតែ៖

- បង្កើតលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) សម្រាប់ទូរសព្ទចល័តដែលមានលេខពី 8-16 ខ្ទង់ យ៉ាងហោចណាស់ត្រូវមានអក្សរធំមួយ អក្សរតូចមួយ លេខ និង តួអក្សរពិសេសមួយ
- មិនត្រូវបង្ហាញលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) របស់អ្នកទៅនរណាម្នាក់ឡើយ
- មិនអនុញ្ញាតឱ្យនរណាម្នាក់ផ្សេងទៀតឃើញពេលលោកអ្នកបញ្ចូលលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) របស់លោកអ្នកឡើយ
- ត្រូវចងចាំលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) របស់លោកអ្នក និងមិនត្រូវកត់ត្រាលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) របស់លោកអ្នកនៅកន្លែងណាមួយឡើយ
- កុំជ្រើសរើសលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ដែលងាយស្រួលសម្គាល់ជាមួយលោកអ្នក ឧទាហរណ៍ ថ្ងៃខែឆ្នាំកំណើត លេខរថយន្ត លេខទូរស័ព្ទ ឬឈ្មោះរបស់លោកអ្នក
- កុំប្រើលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ដូចគ្នាសម្រាប់គោលបំណងផ្សេងៗទៀត និង
- ផ្លាស់ប្តូរលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) របស់លោកអ្នកជាប្រចាំ

សូមអនុវត្តតាមនីតិវិធីខាងក្រោម ក្នុងករណីប្តូរទូរស័ព្ទថ្មី ភ្លេចលេខសម្ងាត់ ឬបាត់ទូរស័ព្ទដែលបានចុះឈ្មោះ៖

1. ការផ្លាស់ប្តូរ ឬជំនួសទូរស័ព្ទថ្មី៖ លោកអ្នក អាចប្រើទូរស័ព្ទថ្មី ដើម្បីស្កេនកូដ QR RECOVERY ដែលត្រូវបានរក្សាទុកនៅពេលចុះឈ្មោះដំបូង ឬប្រើកូដ QR RECOVERY នៅលើទូរស័ព្ទចាស់ ដោយបញ្ចូលលេខកូដ QR RECOVERY ដើម្បីផ្ទេរគណនីរបស់អ្នកទៅទូរស័ព្ទថ្មី។
2. ភ្លេចលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ឬបាត់ទូរស័ព្ទដែលបានចុះឈ្មោះ៖
   i. អតិថិជនអាចទៅកាន់សាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ណាមួយ និងយកអត្តសញ្ញាណប័ណ្ណច្បាប់ដើមមកជាមួយ។
   ii. ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក អាចជួយលោកអ្នកទទួលបានកូដ RECOVERY ថ្មី

## 7. សុវត្ថិភាពទូរស័ព្ទចល័តសម្រាប់ចុះឈ្មោះប្រព័ន្ធបាគង

- គ្រាន់តែភ្ជាប់ ឬទាញយកកម្មវិធីបាគង ពី Play Store ឬ App Store ឬប្រភពសុវត្ថិភាពល្បីៗផ្សេងទៀត។
- ត្រូវពិនិត្យកម្មវិធីដែលកំពុងដំណើរការលើទូរស័ព្ទរបស់លោកអ្នកជានិច្ច។ ប្រសិនបើរកឃើញកម្មវិធីណាដែលមិនស្គាល់ សូមបិទទូរស័ព្ទភ្លាមៗ ដើម្បីជៀសវាងការរីករាលដាលនៃមេរោគ បន្ទាប់មកយកវាទៅកាន់មជ្ឈមណ្ឌលសេវាកម្មទូរស័ព្ទ ដើម្បីត្រួតពិនិត្យ និងសម្អាត។
- កុំទុកទូរស័ព្ទដៃរបស់លោកអ្នក ដោយមិនបានចាក់សោរ និងមិនមានការប្រុងប្រយ័ត្ន។
- សូមប្រយ័ត្នពេលប្រើអ៊ីនធឺណិតសាធារណៈ ព្រោះថាវាងាយស្រួលប្រើប្រាស់ដោយពួក Hacker។
- បិទ/ចេញពីកម្មវិធីភ្លាមៗ បន្ទាប់ពីប្រើប្រាស់សេវាកម្មទូទាត់បាគង។
- សូមថែរក្សាទូរស័ព្ទដែលបានចុះឈ្មោះសម្រាប់ការប្រើប្រាស់សេវាកម្មរបស់ធនាគារ។ ជូនដំណឹងដល់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ភ្លាមៗ ប្រសិនបើទូរស័ព្ទរបស់លោកអ្នកបាត់ ឬត្រូវបានគេលួច។
- ប្រសិនបើទូរស័ព្ទរបស់លោកអ្នកត្រូវផ្លាស់ប្តូរ ឬលក់ លោកអ្នកដាច់ខាតត្រូវតែលុបកម្មវិធីបាគង ចេញពីទូរស័ព្ទរបស់លោកអ្នក។
- ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយឡើយ ប្រសិនបើលោកអ្នកមិនគោរពតាមលក្ខខណ្ឌទាំងនេះយ៉ាងតឹងរ៉ឹង។

## 8. គណនីបាគង

ប្រព័ន្ធបាគង នឹងបង្កើតគណនីបាគង ដោយស្វ័យប្រវត្តិជាប្រាក់រៀល និងដុល្លារអាមេរិក បន្ទាប់ពីអតិថិជនបានចុះឈ្មោះប្រើប្រាស់សេវាទូទាត់បាគងដោយជោគជ័យ។

## 9. លក្ខខណ្ឌនៃការប្រើប្រាស់គណនីបាគង

- មិនមានអត្រាការប្រាក់
- មិនតម្រូវអោយដាក់ប្រាក់ដំបូងទេ
- សមតុល្យអប្បបរមាគឺសូន្យ (0)
- ប្រតិបត្តិការដែលធ្វើឡើងដោយប្រើគណនីបាគង រួមមានការដាក់សាច់ប្រាក់ ការដកសាច់ប្រាក់ ការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រ ការទូទាត់បាគង និងសេវាកម្មផ្សេងទៀតដែលអាចនឹងធ្វើឡើងនៅពេលក្រោយ អាស្រ័យលើការសម្រេចចិត្តរបស់ធនាគារជាតិនៃកម្ពុជា។
- មានការកំណត់ចំនួនទឹកប្រាក់អតិបរមាការនៃផ្ទេរប្រាក់ប្រចាំថ្ងៃនៅលើគណនីបាគង អាស្រ័យលើស្ថានភាពការស្គាល់អតិថិជន (KYC)

  - KYC មូលដ្ឋាន៖ ទឹកប្រាក់អតិបរមាប្រចាំថ្ងៃគឺ 500 ដុល្លារ និង 2,000,000 រៀល
  - KYC ផ្នែកណាមួយ៖ ទឹកប្រាក់អតិបរមាប្រចាំថ្ងៃគឺ 3,000 ដុល្លារ និង 12,000,000 រៀល
  - KYC ពេញលេញ៖ ទឹកប្រាក់អតិបរមាប្រចាំថ្ងៃគឺ 10,000 ដុល្លារ និង 40,000,000 រៀល
- ការដកប្រាក់/ដាក់ប្រាក់ពី/ក្នុងគណនីបាគង តាមរយៈម៉ាស៊ីនអេធីអឹម មិនអាចធ្វើទៅបានទេ។ អតិថិជនអាចដកប្រាក់ ឬដាក់ប្រាក់តាមបញ្ជរសាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ឬធនាគារសមាជិកបាគងផ្សេងៗទៀត។
- មិនមានកាលបរិច្ឆេទផុតកំណត់នៅលើគណនីបាគងទេ ប៉ុន្តែគណនីនឹងក្លាយទៅជាអសកម្ម ប្រសិនបើសមតុល្យគណនីលើសពីសូន្យ និងអសកម្មរយៈពេល 365 ថ្ងៃ (មិនមានប្រតិបត្តិការដែលធ្វើឡើងដោយអតិថិជន) ព្រោះគណនីអសកម្មបែបនេះនឹងមិនអាចធ្វើប្រតិបត្តិការចូល-ចេញដូចធម្មតាបានទេ ហើយវាត្រូវបានបិទដោយស្វ័យប្រវត្តិ។
- សមតុល្យក្នុងគណនីដែលលោកអ្នកមិនបានប្រើប្រាស់អស់រយៈពេលដប់ (10) ឆ្នាំជាប់ៗគ្នា នឹងត្រូវផ្ទេរទៅធនាគារជាតិនៃកម្ពុជា ដើម្បីគ្រប់គ្រងបន្តតាមនីតិវិធីច្បាប់។

## 10.សំណង

លោកអ្នក យល់ព្រមដោយគ្មានលក្ខខណ្ឌក្នុងការទាមទារសំណង និងទូទាត់សងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក នូវរាល់ការទាមទារ ការតម្រូវ សកម្មភាពនានា ទំនួលខុសត្រូវ ការចំណាយ ការបាត់បង់ ឬការចំណាយណាមួយមកលើធនាគារដែលបណ្តាលមកពីប្រតិបត្តិការសេវាទូទាត់បាគង និងការបំពានណាមួយរបស់លោកអ្នកមកលើកិច្ចព្រមព្រៀងនេះ។ នេះរាប់បញ្ចូលទាំងប្រតិបត្តិការដែលមិនជោគជ័យណាមួយដែលបានធ្វើឡើងលោកអ្នក ដើម្បីធានាថារាល់ជំហានដែលយកមកអនុវត្ត ដើម្បីទប់ស្កាត់ការប្រើប្រាស់សេវាទូទាត់បាគងដោយគ្មានការអនុញ្ញាត។

## 11. ការបញ្ចប់ ឬការលុបចោល

លោកអ្នក ត្រូវតែដក ឬផ្ទេរសាច់ប្រាក់ពីគណនីរបស់លោកអ្នកដើម្បីធ្វើសមតុល្យទៅជាសូន្យ មុនពេលបញ្ចប់ ឬលុបចោលប្រព័ន្ធបាគង។

លោកអ្នក អាចបញ្ចប់ ឬលុបចោលប្រព័ន្ធបាគងដោយខ្លួនឯងនៅលើទូរស័ព្ទរបស់លោកអ្នកដែលបានចុះឈ្មោះសម្រាប់សេវាកម្មនេះ។

## 12.ថ្លៃសេវា

លោកអ្នក យល់ព្រមបង់ថ្លៃសេវាដែលកំណត់ដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ទាក់ទងនឹងការប្រើប្រាស់សេវាទូទាត់លើប្រព័ន្ធបាគង។ លោកអ្នក យល់ព្រមថា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក អាចនឹងដកថ្លៃសេវាទាំងនេះដោយផ្ទាល់ពីក្នុងគណនីសម្រាប់ទូទាត់របស់លោកអ្នក ដោយមិនមានការជូនដំណឹងជាមុន។

## 13.ការទូទាត់ និងផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក មិនមានកាតព្វកិច្ចក្នុងការពិនិត្យមើលថាព័ត៌មានលំអិតដែលផ្តល់ដោយអតិថិជនក្នុងកម្មវិធីបាគងត្រឹមត្រូវដែរឬទេ។

កំហុសណាមួយក្នុងការបញ្ចូលព័ត៌មានលំអិតទាំងនេះ អាចបណ្តាលឱ្យមានការទូទាត់ខុសលេខគណនី ឬខុសចំនួនទឹកប្រាក់ និងខុសរូបិយប័ណ្ណ ឬការណែនាំមិនត្រូវបានធ្វើឡើងទាល់តែសោះ។ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក មិនទទួលខុសត្រូវចំពោះភាពមិនត្រឹមត្រូវណាមួយនៅក្នុងការណែនាំដែលផ្តល់ដោយលោកអ្នក ឬទទួលខុសត្រូវចំពោះការបាត់បង់ណាមួយដែលកើតឡើងពីភាពមិនត្រឹមត្រូវនៅក្នុងព័ត៌មានដែលបានផ្តល់ដោយលោកអ្នកនោះឡើយ។

ការទូទាត់ និងការផ្ទេរប្រាក់ទៅគណនីណាមួយតាមប្រព័ន្ធអេឡិចត្រូនិក គឺមិនអាចដកត្រឡប់វិញបានទេ នៅពេលដែលការទូទាត់ ឬដំណើរការផ្ទេរប្រាក់របស់លោកអ្នកត្រូវបានធ្វើរួចរាល់។ លោកអ្នកត្រូវ ជូនដំណឹងជាបន្ទាន់ទៅកាន់ធនាគារ ប្រសិនបើព័ត៌មានអំពីការផ្ទេរប្រាក់ណាមួយមិនត្រឹមត្រូវដែលបានបង្ហាញនៅលើរបាយការណ៍គណនីរបស់លោកអ្នក។

លោកអ្នក មានកាតព្វកិច្ចគោរពយ៉ាងពេញលេញ និងសហការជាមួយស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតសម្រាប់ប្រតិបត្តិការទូទាត់ ឬប្រតិបត្តិការការផ្ទេរប្រាក់ដែលបានធ្វើឡើងតាមប្រព័ន្ធបាគង។

លោកអ្នក ទទួលស្គាល់ថា លោកអ្នក អាចនឹងទទួលបានទឹកប្រាក់ ឬការទូទាត់ដោយចៃដន្យពីគណនីផ្សេងទៀតនៅក្រោមស្ថាប័នហិរញ្ញវត្ថុណាមួយ (ដោយកំហុសរបស់មនុស្ស ឬប្រព័ន្ធដំណើរការខុសប្រក្រតី) តាមប្រព័ន្ធទូទាត់បាគង។ ក្នុងករណីបែបនេះ លោកអ្នកមានកាតព្វកិច្ចគោរព និងសហការជាមួយស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ដើម្បីដោះស្រាយវិវាទដែលតម្រូវ ។

លោកអ្នក ទទួលស្គាល់ថាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក មានសិទ្ធិបង្កក ឬរក្សាសមតុល្យគណនីបាគងរបស់លោកអ្នកភ្លាមៗ ហើយដកប្រាក់ទាំងនោះ ក្នុងករណីវិវាទត្រូវបានលើកឡើងពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។ បន្ទាប់មក លោកអ្នកមានកាតព្វកិច្ចគោរពតាម និងសហការគ្នាដើម្បីដោះស្រាយបណ្តឹងវិវាទនោះ។

លោកអ្នក មានកាតព្វកិច្ចត្រូវទូទាត់ត្រលប់មកវិញនូវចំនួនទឹកប្រាក់នៃប្រតិបត្តិការ ដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងវិវាទទៅភាគីម្ខាងទៀតដែលមានភស្តុតាងបញ្ជាក់ថា ចំនួនទឹកប្រាក់នៃប្រតិបត្តិការដែលបានកើតឡើងដោយអចេតនាចូលទៅក្នុងគណនីបាគងរបស់ខ្លួន ដោយមិនកំណត់ថាជាកំហុសរបស់មនុស្ស ឬប្រព័ន្ធដំណើរការខុសប្រក្រតីឡើយ។ លោកអ្នក ក៏មានសិទ្ធិបង្ហាញករណីរបស់លោកអ្នកនៅក្នុងបណ្តឹងវិវាទ ដោយប្រើប្រាស់ព័ត៌មានដែលមានសុពលភាពដូចជា របាយការណ៍គណនី និងរូបថតអេក្រង់នៃបង្កាន់ដៃសម្រាប់ធ្វើការបញ្ជាក់ផងដែរ។

ក្នុងករណីដែលលោកអ្នកមិនប្រគល់ចំនួនទឹកប្រាក់នៃប្រតិបត្តិការ ដែលបានលើកឡើងក្នុងបណ្តឹងវិវាទនោះទេ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ត្រូវរាយការណ៍អំពីចំនួនប្រាក់ប្រតិបត្តិការនោះ ក្នុងទំរង់ជាប្រាក់កម្ចីដែលមិនបានបង់នៅក្រោមប្រវត្តិរូបរបស់លោកអ្នក ទៅកាន់ការិយាល័យឥណទានកម្ពុជា (CBC) តាមគោលការណ៍របស់ធនាគារជាតិនៃកម្ពុជា (NBC)។

## 14.ការទទួលខុសត្រូវរបស់ធនាគារ

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក មិនធានាថាការប្រើប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងមិនមានផលវិខានណាមួយនោះឡើយ។ បន្ថែមពីលើកាលវិភាគនៃការផ្អាកដំណើរការប្រព័ន្ធណាមួយរបស់ធនាគារ ដែលបានជូនដំណឹងទៅលោកអ្នកដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក លោកអ្នកទទួលស្គាល់ថាសេវាទូទាត់តាមប្រព័ន្ធបាគងរបស់ធនាគាជាតិនៃកម្ពុជា តាមរយៈធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក អាចនឹងរង

ផលប៉ះពាល់ ឬអាក់ខានដែលអាចបណ្តាលមកពីកត្តាផ្សេងៗ រាប់បញ្ចូលទាំងបញ្ហាបច្ចេកទេស ឬបញ្ហាដំណើរការរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ឬបញ្ហាផ្សេងៗដែលមិនបានស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ដូចជា បញ្ហាបច្ចេកទេសជាមួយអ៊ីនធឺណិត ឬការខូតខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជាកំហូចខ្សែទូរស័ព្ទ ឬការរំខានដល់ប្រព័ន្ធឌីជីថល។

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ទទួលខុសត្រូវចំពោះម្ចាស់គណនី សម្រាប់ការបាត់បង់ណាមួយ ដែលបណ្តាលមកពីបញ្ហាប្រព័ន្ធបច្ចេកទេសរបស់ធនាគារទៅលើប្រតិបត្តិការតាមការណែនាំរបស់លោកអ្នក តាមរយៈប្រព័ន្ធរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក។ ប្រសិនបើលោកអ្នកបានដឹង ឬ ត្រូវបានដឹងថាប្រព័ន្ធបច្ចេកទេសរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក មិនអាចប្រើប្រាស់បាន ឬដំណើរការខុសប្រក្រតីនោះ ទំនួលខុសត្រូវរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ម. ក នឹងត្រូវមានកំណត់ត្រឹមការកែតម្រូវភាពមិនត្រឹមត្រូវនៅក្នុងគណនីរបស់លោកអ្នក និងទូទាត់ថ្លៃសេវាណាមួយដូចបានកំណត់។

ម្ចាស់គណនីត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃព័ត៌មាន ដែលលោកអ្នកបានបញ្ចូលទៅកាន់ប្រព័ន្ធទូទាត់បាគងរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈធនាគារជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ។ ធនាគារជេ ត្រាស់ រ៉ូយ៉ាល់ ម.ក មិនទទួលខុសត្រូវចំពោះភាពមិនត្រឹមត្រូវ ឬភាពមិនពេញលេញណាមួយ ក្នុងការបញ្ចូលព័ត៌មានដោយលោកអ្នកឡើយ។ កំណត់ត្រារបស់ធនាគារជេ ត្រាស់ រ៉ូយ៉ាល់ ម.ក អំពីព័ត៌មាន និងទិន្នន័យដែលបានបញ្ចូល ឬ ផ្ទេរដោយលោកអ្នកនឹងត្រូវបានកំណត់ថាសព្វគ្រប់។

ធនាគារជេ ត្រាស់ រ៉ូយ៉ាល់ ម.ក នឹងមិនទទួលខុសត្រូវចំពោះការខូចខាត ការបាត់បង់ ការលុបទិន្នន័យដោយសារកំហុស ឬដំណើរការខុសប្រក្រតីនៃទូរស័ព្ទចល័តរបស់លោកអ្នក ឬឧបទ្ទវហេតុផ្សេងៗ ដូចជាសង្គ្រាម ភ្លើង រញ្ជួយដី ព្យុះ ទឹកជំនន់ជាដើម ដែលលើសពីការគ្រប់គ្រងរបស់ភាគីទាំងពីរ។

## 15.ការបង្ហាញអំពីព័ត៌មានគណនី

លោកអ្នក យល់ព្រមឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក បង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកទៅកាន់ ៖

ក) អង្គភាពណាមួយដែលស្ថិតក្នុងការរៀបចំ ឬសម្ព័ន្ធភាពជាមួយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ។

ខ) អ្នកផ្តល់សេវាណាមួយដែលធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ចូលរួមអនុវត្ត ឬជួយដល់មុខងារ និងសកម្មភាពរបស់ខ្លួន និង

គ) និយតករ ស្ថាប័នរដ្ឋាភិបាល ស្ថាប័នអនុវត្តច្បាប់ និងតុលាការ នៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា។

## 16.ការប្រែប្រួលនៃ ខនិងលក្ខខណ្ឌ និងការកំណត់ថ្លៃ

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក អាចធ្វើការកែប្រែទៅលើ ខចែង និងលក្ខខណ្ឌ និងការកំណត់ថ្លៃប្រសិនបើតម្រូវដោយច្បាប់ ឬគ្រប់ពេលវេលាទាំងអស់ ដោយធ្វើការជូនដំណឹងដល់លោកអ្នក មិនតិចជាង ៣០ ថ្ងៃ មុនពេលធ្វើការផ្លាស់ប្តូរតាមរយៈ៖

- ការជូនដំណឹងដោយផ្ទាល់ទៅលោកអ្នក (តាមរយៈរបាយការណ៍គណនី ឬ តាមបណ្តាញសង្គមជាផ្លូវការរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ដូចជា SMS  Facebook ឬ Telegram)
- ការជូនដំណឹងនៅតាមបណ្តាសាខា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក ឬ គេហទំព័រ ឬ
- ផ្សព្វផ្សាយនៅលើសារព័ត៌មានល្បីៗនៅក្នុងស្រុក។

ភ្លាមៗក្រោយពីការជូនដំណឹង និងផ្សព្វផ្សាយព័ត៌មានទាំងនេះ លោកអ្នកត្រូវបានសន្មតថាបានទទួលព័ត៌មានទាំងនេះ។

ប្រសិនបើលោកអ្នកបន្តការប្រើប្រាស់សេវាទូទាត់បាគង តាមរយៈធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម. ក បន្ទាប់ពីការជូនដំណឹងនេះ លោកអ្នកនឹងត្រូវបានចាត់ទុកថាលោកអ្នកបានយល់ព្រមទទួលនូវការប្រែប្រួលទាំងអស់នោះ។

## 17. លក្ខខណ្ឌផ្សេងៗទៀត

ក) ក្នុងករណីដែលមានភាពមិនស៊ីសង្វាក់គ្នារវាងភាសាអង់គ្លេស និងភាសាខ្មែរនៃឯកសារនេះ នោះឯកសារជាភាសាខ្មែរត្រូវមានវិសាលភាពលើភាសាអង់គ្លេស។

ខ) ខ និងលក្ខខណ្ឌនេះត្រូវបានគ្រប់គ្រង និងបកស្រាយក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំបានអាន និងទទួលយកនូវរាល់ ខ និងលក្ខខណ្ឌដូចមានចែងខាងលើ។